**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

លេខ : ០៥៩/១៧ ក.ប/ស.ជ.ណ.ព.ក

# សេចក្តីជូនដំណឹង

ដើម្បីប្រតិបត្តិការប្រព័ន្ធឡចំហាយឱ្យមានសុវត្ថិភាព និងបង្ការហានិភ័យនៃការផ្ទុះជាយថាហេតុ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមណែនាំដល់ម្ចាស់សហគ្រាស គ្រឹះស្ថាន ជាពិសេសសហគ្រាស គ្រឹះស្ថានកាត់ដេរសំលៀកបំពាក់ និងផលិតស្បែកជើងទាំងអស់អនុវត្តឱ្យបានហ្មត់ចត់នូវវិធានការដូចខាងក្រោម៖

១- ត្រូវប្រើប្រាស់ឡចំហាយដែលមានប្រព័ន្ធធានាសុវត្ថិភាពស្របតាមបទប្បញ្ញត្តិជាធរមាន។

២- ត្រូវរៀបចំដំឡើងប្រព័ន្ធឡចំហាយតាមលក្ខណៈបច្ចេកទេសពីស្ថាប័នជំនាញពាក់ព័ន្ធ ដោយត្រូវចាក់ភ្ជាប់ជើងទម្រឡចំហាយជាមួយបេតុង និងរៀបចំវិធានការការពារសុវត្ថិភាព មុនពេលប្រតិបត្តិការប្រព័ន្ធឡចំហាយ។

៣- ត្រូវរៀបចំឱ្យមានបទបញ្ជាការងារ អំពីសុវត្ថិភាពនៃការប្រើប្រាស់ឡចំហាយ សញ្ញាការសុខភាពនិងសុវត្ថិភាពការងារដែលងាយយល់ ងាយមើលឃើញ និងថែរក្សាឱ្យបានស្អាតជានិច្ចសម្រាប់អ្នកបញ្ជាប្រព័ន្ធឡចំហាយ។

៤- ត្រូវមើលថែទាំ និងត្រួតពិនិត្យប្រព័ន្ធឡចំហាយជាប្រចាំថ្ងៃ ប្រចាំសប្តាហ៍ ប្រចាំខែ និងប្រចាំឆ្នាំ ដោយអ្នកជំនាញ និងមានកំណត់ត្រាឱ្យបានត្រឹមត្រូវ។

៥- អ្នកបញ្ជាឡចំហាយត្រូវមានវត្តមានជាប្រចាំ ដើម្បីតាមដានសម្ពាធ កម្រិតទឹក និងកម្តៅឡចំហាយដើម្បីបង្ការកុំឱ្យមានការផ្ទុះឡើង។

៦- ត្រូវរៀបចំឱ្យមានការវាយតម្លៃហានិភ័យនៃការប្រើប្រាស់ប្រព័ន្ធឡចំហាយ ដោយអ្នកជំនាញ ដើម្បីការពារហានិភ័យនៃការផ្ទុះ និងផ្តល់វិធានការការពារប្រកបដោយប្រសិទ្ធភាព។

៧- ត្រូវចាត់តាំងឱ្យមានអ្នកទទួលខុសត្រូវ និងអ្នកបញ្ជាឡចំហាយ ដែលបានទទួលការអប់រំបណ្តុះបណ្តាលចំមុខជំនាញឱ្យបានត្រឹមត្រូវ ស្របតាមប្រកាសលេខ១៧៦ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៣ ស្តីពីការអប់រំអនាម័យ និងបច្ចេកទេសសន្តិសុខការងារដល់កម្មករនិយោជិត ប្រតិភូបុគ្គលិក និងសហជីព។

៨- ត្រូវមានអ្នកជំនាញឯកទេសផ្នែកឡចំហាយ ដើម្បីជួសជុល ឬផ្លាស់ប្តូរផ្នែកណាមួយនៃប្រព័ន្ធឡចំហាយនៅពេលមិនដំណើរការ។

៩- មិនត្រូវបិទចរន្តអគ្គិសនីនៅពេលឡចំហាយកំពុងដំណើរការ ដើម្បីតាមដានសញ្ញាអាសន្នដែលកើតឡើងពីកំណើនសម្ពាធក្នុងឡចំហាយ។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សង្ឃឹមយ៉ាងមុតមាំថា ម្ចាស់សហគ្រាស គ្រឹះស្ថានទាំងអស់នឹងអនុវត្តឱ្យបានត្រឹមត្រូវតាមសេចក្តីជូនដំណឹងនេះ ប្រកបដោយប្រសិទ្ធភាពខ្ពស់។

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ មេសា ឆ្នាំ២០១៧

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩